ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ



ELECTRICITE DU CAMBODGE

**អគ្គិសនីកម្ពុជា**

លេខ: ០៨៣៤ សរណ.អក.ចប

## សេចក្តីជូនដំណឹង
## ស្តីពី ការជ្រើសរើសបុគ្គលិក

អគ្គិសនីកម្ពុជា សូមជម្រាបជូនដំណឹងដល់សាធារណៈជនថា អគ្គិសនីកម្ពុជាត្រូវការជ្រើសរើស**បុគ្គលិកអនាម័យ-ថៃសួន** ចំនួន១៥រូប ដើម្បីចូលបម្រើការងារនៅតាមបណ្តាអនុស្ថានីយដូចខាងក្រោម នៅអង្គភាពបណ្តាញបញ្ជូន នៃនាយកដ្ឋានបញ្ជូនអគ្គិសនី :

- **អនុស្ថានីយទី៣** ចំនួន០១រូប
- **អនុស្ថានីយរាម** ចំនួន០១រូប
- **អនុស្ថានីយឧត្តរមានជ័យ** ចំនួន០១រូប
- **អនុស្ថានីយមណ្ឌលគិរី** ចំនួន០១រូប
- **អនុស្ថានីយល្វាឯម** ចំនួន០១រូប
- **អនុស្ថានីយសំរោងធំ** ចំនួន០១រូប
- **អនុស្ថានីយបុទុមសាគរ** ចំនួន០១រូប
- **អនុស្ថានីយក្រគរស្វាអន្សា** ចំនួន០១រូប
- **អនុស្ថានីយស្លង** ចំនួន០១រូប
- **អនុស្ថានីយកោះកុង** ចំនួន០១រូប
- **អនុស្ថានីយកោះកុងស៊ីជី** ចំនួន០១រូប
- **អនុស្ថានីយទំពអាកាស** ចំនួន០១រូប
- **អនុស្ថានីយបាត់ដំបង(Solar Farm)** ចំនួន០១រូប
- **អនុស្ថានីយព្រែកប្រសព្វ** ចំនួន០១រូប
- **អនុស្ថានីយអូរខ្វាវ** ចំនួន០១រូប

*- **<u>លក្ខណ:សម្បត្តិបេក្ខជន</u>** :

+បេក្ខជនទាំង០២ភេទ មានអាយុចាប់ពី១៨ឆ្នាំ ដល់៣៥ឆ្នាំ

+បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធE.VII.១ ក្នុងពេលសាកល្បងការងារ០៣ខែ ទទួលបាន៩០%

+កម្រិតវប្បធម៌ : ចេះអាន និងសរសេរអក្សរខ្មែរបាន

+បេក្ខជនត្រូវមានសុខភាពល្អ និងកាយសម្បទាមាំមួន។

*- ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារនៅអគ្គិសនីកម្ពុជាបេក្ខជនត្រូវទាញយក(**Download**) ដោយផ្ទាល់ពីក្នុងគេហទំព័ររបស់អគ្គិសនីកម្ពុជា គឺ : **www.EDC.com.kh** ត្រង់ចំណុចព័ត៌មានវិជ្ជាជីវៈ ដោយចុចលើពាក្យសុំចូលប្រឡងដើម្បីបម្រើការងារនៅអគ្គិសនីកម្ពុជា។

*- បេក្ខជនត្រូវបំពេញពាក្យសុំចូលបម្រើការងារ និងត្រូវអញ្ជើញមកដាក់ពាក្យប្រឡងដោយផ្ទាល់ខ្លួន និងភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនច្បាប់ដើមមកជាមួយ។ ករណីបេក្ខជនមិនបានអញ្ជើញមកដាក់ពាក្យដោយផ្ទាល់ទេ អគ្គិសនីកម្ពុជាមិនទទួលពាក្យជូនឡើយ។

*- បេក្ខជនដាក់ពាក្យត្រូវពាក់ម៉ាស់ និងរក្សាគម្លាតសុវត្ថិភាពឲ្យបានត្រឹមត្រូវ។

*- **បេក្ខជនត្រូវមកដាក់ពាក្យ និងភ្ជាប់មកជាមួយនូវ** :

- ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារ នៅអគ្គិសនីកម្ពុជា ចំនួន០១ច្បាប់
- ប្រវត្តិរូបសង្ខេប មានបិទរូបថត ៤ x ៦ ចំនួន០១ច្បាប់
- កិច្ចសន្យា សម្រាប់បំពេញពាក្យសុំចូលបម្រើការងារ និងកិច្ចសន្យាការងារ ចំនួន០១ច្បាប់
- សលាកប័ត្របេក្ខជន ចំនួន០១ច្បាប់
- ច្បាប់ចម្លងសញ្ញាប័ត្រចំណេះដឹងទូទៅ និងសញ្ញាប័ត្រជំនាញ ចំនួន០១ច្បាប់
- តារាងពិន្ទុ(TRANSCRIPT) ចំនួន០១ច្បាប់
- ច្បាប់ដើម និងច្បាប់ចម្លងនៃអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ចំនួន០១ច្បាប់

*- ចំពោះបែបបទមួយចំនួនទៀត ដូចមានចែងក្នុងឧបសម្ព័ន្ធI នៃលក្ខន្តិកៈបុគ្គលិកអគ្គិសនីកម្ពុជា បេក្ខជនប្រឡងជាប់ មានកាតព្វកិច្ចបំពេញបន្ថែម។

*- **ទីកន្លែងទទួលពាក្យ** : សាលប្រជុំនាយកដ្ឋានរដ្ឋបាល នៅកីឡដ្ឋានបាល់ទាត់អគ្គិសនីកម្ពុជា(អតីតរោងចក្រអគ្គិសនីទី៤)។

ចាប់ពីថ្ងៃផ្សាយដំណឹងនេះ ហូតដល់ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១ រៀងរាល់ថ្ងៃធ្វើការ

- **ពេលព្រឹក** ចាប់ពីម៉ោង០៨:០០ ដល់ម៉ោង១១:៣០ **ពេលល្ងាច** ចាប់ពីម៉ោង១៤:០០ ដល់ម៉ោង១៧:០០

*- **ព័ត៌មានផ្សេងៗ**:សូមអញ្ជើញមកទាក់ទង ការិយាល័យរដ្ឋបាល ទីស្នាក់ការកណ្ដាល អគ្គិសនីកម្ពុជា ឬតាមរយៈលេខទូរស័ព្ទ ០២៣ ៧២៣ ៩៧១ និង ០២៣ ៧២៤ ៧៧១។

ថ្ងៃព្រហស្បតិ៍ ៧កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១

ស.រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី

អគ្គនាយកអគ្គិសនីកម្ពុជា

អគ្គនាយករង

ELECTRICITE DU CAMBODGE

អេង_គន្ធា

**បញ្ជាក់**

- សេចក្ដីជូនដំណឹងនេះ ធ្វើការផ្សព្វផ្សាយជាផ្លូវការតាមរយៈគេហទំព័ររបស់អគ្គិសនីកម្ពុជា គឺ : www.EDC.com.kh ត្រង់ចំណុច " ព័ត៌មានវិជ្ជាជីវៈ " ។